# គោលនយោបាយស្តីពីការរាយការណ៍

ការផ្លាស់ប្តូរចាប់ផ្តើមជាមួយការអប់រំ

# តារាងមាតិកា

1. គោលបំណង ........ 2
2. បរិបទ ........ 2
2.1. គោលបំណងរបស់យើង ........ 2
2.2. ភាគីពាក់ព័ន្ធ ........ 3
3. និយមន័យ ........ 3
4. គោលនយោបាយ និងគោលការណ៍គោលនយោបាយ ........ 4
4.1. គោលនយោបាយ ........ 4
4.2. គោលការណ៍ ........ 5
5. អនុវត្តន៍គោលនយោបាយ ........ 5
5.1. រាយការណ៍ពីការព្រួយបារម្ភ ........ 5
5.2. ការស៊ើបអង្កេតលើការរាយការណ៍ ........ 6
5.3. ការសម្ងាត់ ........ 7
5.4. ការការពារបុគ្គលរាយការណ៍ ........ 8
5.5. បុគ្គលរាយការណ៍ជាប់ពាក់ព័ន្ធនឹងទង្វើខុសច្បាប់ ........ 8
5.6. ការផ្តល់ព័ត៌មានមិនពិត ........ 9
5.7. ការប្រាស្រ័យទាក់ទងជាមួយអ្នករាយការណ៍ ........ 9
5.8. ការគ្រប់គ្រងបុគ្គលដែលរងនូវការចោទប្រកាន់ ........ 9
6. គោលនយោបាយពាក់ព័ន្ធ ........ 10
7. ការគ្រប់គ្រងគោលនយោបាយ ........ 10
ឧបសម្ព័ន្ធ ក - នីតិវិធីរាយការណ៍ ........ 11

# គោលនយោបាយស្តីពីការរាយការណ៍

## 1. គោលបំណង

អង្គការទស្សនៈឥតព្រំដែន ( SeeBeyondBorders) ព្យាយាមធ្វើសកម្មភាពរបស់ខ្លួនប្រកបដោយវិជ្ជាជីវៈ ស្មោះត្រង់ និងដោយសុចរិតភាពគ្រប់ពេលវេលា។ ទោះជាយ៉ាងណាក៏ដោយ អង្គការទាំងអស់ប្រឈមមុខនឹងហានិភ័យនៃការប្រព្រឹត្តគ្មានវិជ្ជាជីវៈ អាកប្បកិរិយាខុសច្បាប់ ព្រហ្មទណ្ឌ ឬការគ្រប់គ្រងមិនត្រឹមត្រូវ។ យើងជឿថាវាជាទំនួលខុសត្រូវរបស់យើងក្នុងការចាត់វិធានការសមស្របដើម្បីកំណត់មុខសញ្ញាស្ថានភាពបែបនេះ និងព្យាយាមដោះស្រាយវា។

យើងប្តេជ្ញាលើកកម្ពស់វប្បធម៌មួយដែលបុគ្គលិក អ្នកហាត់ការ និងអ្នកស្ម័គ្រចិត្តត្រូវបានលើកទឹកចិត្តឱ្យលើកឡើងពីការព្រួយបារម្ភអំពីអាកប្បកិរិយាគ្មានសីលធម៌ និងមិនអាចទទួលយកបាន ហើយដែលអាចរាយការណ៍បានក្នុងបរិយាកាសសុវត្ថិភាព។

គោលបំណងនៃគោលនយោបាយនេះ គឺដើម្បីពង្រឹងគុណតម្លៃស្នូលរបស់យើង ដោយផ្តល់សិទ្ធិអំណាចដល់បុគ្គលិក អ្នកហាត់ការ និងអ្នកស្ម័គ្រចិត្តទាំងអស់ដែលមានបំណងរាយការណ៍អំពីអំពើខុសឆ្គងណាមួយដោយស្មោះត្រង់។

នេះគឺជាឯកសារ«រស់»ហើយនឹងត្រូវបានពិនិត្យ និងធ្វើបច្ចុប្បន្នភាពជាទៀងទាត់នៅពេលដែលបទពិសោធន៍កើនឡើង។

## 2. បរិបទ

### 2.1. គោលបំណងរបស់យើង

គោលបំណងរបស់ អង្គការទស្សនៈឥតព្រំដែន គឺដើម្បីឱ្យកុមារកាន់តែច្រើនបានបញ្ចប់ការសិក្សារបស់ពួកគេនៅកំរិតបឋមសិក្សា និងបន្តទៅរៀននៅអនុវិទ្យាល័យ។

យើងបណ្តុះបណ្តាលគ្រូបង្រៀន អភិវឌ្ឍហេដ្ឋារចនាសម្ព័ន្ធសាលារៀន និងគាំទ្រដល់គ្រួសារម្ចាស់ស្រុក ក្នុងការអប់រំកូនៗរបស់ពួកគេនៅក្នុងប្រទេសកម្ពុជា ដែលជាប្រទេសធ្លាប់ត្រូវបានបំផ្លិចបំផ្លាញដោយសង្គ្រាមប្រល័យពូជសាសន៍ ការគាបសង្កត់ និងការអត់ឃ្លាន។ យើងក៏ធ្វើការដើម្បីកែលម្អប្រព័ន្ធអប់រំនៅកម្ពុជាទាំងមូល ដោយជំរុញលើកទឹកចិត្តឱ្យមានការផ្លាស់ប្តូរជាប្រព័ន្ធនៅគ្រប់កម្រិតនៃរដ្ឋាភិបាល។

យើងស្វែងរកការចូលរួមពីប្រជាជនមកពីប្រទេសអភិវឌ្ឍន៍ក្នុងការងាររបស់យើង ដោយអមជាមួយក្រុមគ្រូបង្រៀនដើម្បីជួយបង្រៀនគ្រូនៅកម្ពុជា និងអញ្ជើញអ្នកស្ម័គ្រចិត្តផ្សេងទៀតឱ្យធ្វើការលើគម្រោងនានា ដែលមានដូចជាការបង្រៀនមេរៀនកីឡា ដល់កុមារបឋមសិក្សា រហូតដល់ការចាក់បេតុង ឬលាបថ្នាំអគារ។

ការផ្តល់ឱកាសឱ្យជនជាតិផ្សេងទៀតទទួលបានបទពិសោធន៍ និងរៀនពីរបៀបរស់នៅបែបអាស៊ី គឺជាមូលដ្ឋានគ្រឹះនៃភាពជោគជ័យរបស់យើង និងស្គាល់ចំណុចខុសគ្នាសំខាន់ៗ។ ការលើកកម្ពស់ការគោរពទៅវិញទៅមក និងសេចក្តីថ្លៃថ្នូរ ការគ្រប់គ្រងនិងការចាត់ចែងតាមបែបតំបន់ដែលកំពុង និងការកសាងភាពអាស្រ័យតិចតួច និងនិរន្តរភាពអតិបរមា គឺជារបៀបធ្វើការដែលយើងប្រកាន់យក។

### 2.2. ភាគីពាក់ព័ន្ធ

- ក្រុមប្រឹក្សាភិបាល និងគណៈគ្រប់គ្រងអង្គការទស្សនៈឥតព្រំដែន
- បុគ្គលិក និងអ្នកស្ម័គ្រចិត្តដែលធ្វើការនៅក្នុងប្រទេសផ្សេងៗគ្នា
- ម្ចាស់ជំនួយ និងអ្នកគាំទ្រ – រួមទាំងអ្នកដែលបានចូលរួមនៅក្នុងកម្មវិធីក្នុងស្រុក និងអ្នកដែលរៀបចំផែនការកម្មវិធី

## 3. និយមន័យ

«**ការរាយការណ៍**» ត្រូវបានកំណត់ថាជាការបង្ហាញរឿងដោយចេតនានិងដោយស្ម័គ្រចិត្តស្តីពីអំពើខុសឆ្គងរបស់បុគ្គល ឬអង្គភាព តាមរយៈជាបុគ្គលដែលមានទិន្នន័យ ដឹងហេតុការណ៍ ឬមានព័ត៌មានអំពីកំហុសឆ្គងជាក់ស្តែង ការសង្ស័យ ឬរំពឹងថាអាចប្រព្រឹត្តខុសឆ្គងនៅក្នុងអង្គការ។

«**បុគ្គលរាយការណ៍**» ត្រូវបានកំណត់ថាជាបុគ្គលិក ឬអ្នកស្ម័គ្រចិត្តដែលប៉ុនប៉ង ឬចង់ធ្វើការរាយការណ៍ពាក់ព័ន្ធនឹងអំពើខុសឆ្គងក្រោមគោលនយោបាយនេះ ហើយមានបំណងចង់ទទួលបានការការពារខ្លួនគាត់ដូចដែលផ្តល់ឱ្យដោយគោលនយោបាយនេះ។

"**ទង្វើខុសឆ្គង**" រួមបញ្ចូល (ប៉ុន្តែមិនកំណត់ចំពោះ)៖

- ការបំពានកាតព្វកិច្ចផ្លូវច្បាប់ (រួមទាំងការធ្វេសប្រហែស ការបំពានកិច្ចសន្យា ការបំពានច្បាប់រដ្ឋបាល)

- បទល្មើសព្រហ្មទណ្ឌ
- ការគ្រប់គ្រងមូលនិធិមិនត្រឹមត្រូវ
- ទង្វើជាក់ស្តែង ឬមានការសង្ស័យថាមានការក្លែងបន្លំ និងមានអំពើពុករលួយ
- ការបំពានសិទ្ធិអំណាច
- ហានិភ័យសុខភាព និងសុវត្ថិភាព រួមទាំងហានិភ័យដល់សាធារណជន និងបុគ្គលិកដទៃទៀត
- ការខូចខាតដល់បរិស្ថាន
- ការប្រើប្រាស់មូលនិធិ ឬទ្រព្យសម្បត្តិរបស់អង្គការដោយគ្មានការអនុញ្ញាត
- អំពើហិង្សា/ការរំលោភបំពានផ្លូវភេទ ពាក្យសំដី ឬផ្លូវកាយ
- អាកប្បកិរិយាអសីលធម៌ផ្សេងទៀត ឬ
- ការលាក់បាំងនូវចំណុចណាមួយខាងលើ

**"បុគ្គលិក និងអ្នកស្ម័គ្រចិត្ត"** គឺជាអ្នកដែលបានចុះកិច្ចសន្យាជាមួយ អង្គការទស្សនៈឥតព្រំដែន មិនថាជាកិច្ចសន្យាអចិន្ត្រៃយ៍ កិច្ចសន្យារយៈពេលថេរ ឬកិច្ចព្រមព្រៀងស្ម័គ្រចិត្ត។

**«ក្រុមការងារ»**គឺជាបុគ្គលិក និងអ្នកស្ម័គ្រចិត្ត។

## 4. គោលនយោបាយ និងគោលការណ៍គោលនយោបាយ

### 4.1. គោលនយោបាយ

អង្គការទស្សនៈឥតព្រំដែន ស្វែងរកការផ្តល់ជូនដល់បុគ្គលិក អ្នកហាត់ការ និងអ្នកស្ម័គ្រចិត្ត នូវបរិយាកាសការងារបែបទ្រទ្រង់ ដែលអោយពួកគេមានអារម្មណ៍ថាអាចលើកឡើងពីបញ្ហាកង្វល់ស្រប ច្បាប់បាន។ យើងនឹងចាត់វិធានការដើម្បីការពារក្រុមការងារពីការធ្វើឱ្យប៉ះពាល់ ឬការបណ្តេញចេញ ប្រសិនបើពួកគេបានរាយការណ៍ពីការសង្ស័យ ឬទង្វើខុសជាក់ស្តែង។ យើងអនុវត្តតាមច្បាប់ពាក់ព័ន្ធស្តីពី ការលាតត្រដាងនូវអំពើខុសឆ្គងនៅកន្លែងធ្វើការដូចខាងក្រោម៖

- នៅប្រទេសអូស្ត្រាលី៖ ច្បាប់សាជីវកម្មឆ្នាំ ២០០១

- នៅចក្រភពអង់គ្លេស៖ ច្បាប់ស្តីពីការបង្ហាញផលប្រយោជន៍សាធារណៈឆ្នាំ 1998 ដែលធ្វើវិសោធនកម្មច្បាប់ស្តីពីសិទ្ធិការងារឆ្នាំ 1996
- នៅប្រទេសអៀរឡង់៖ ច្បាប់ស្តីពីការការពារអ្នករាយការណ៍ឆ្នាំ 2014

នាពេលបច្ចុប្បន្ននេះ ច្បាប់ប្រឆាំងអំពើពុករលួយនៅកម្ពុជាមានការការពារតិចតួចបំផុត សម្រាប់អ្នកផ្តល់ព័ត៌មាន ដូច្នេះហើយ ច្បាប់សាជីវកម្មឆ្នាំ 2001 (អូស្ត្រាលី) នឹងការពារអ្នកផ្តល់ព័ត៌មាននៅក្នុងអង្គការ ទស្សនៈឥតព្រំដែន កម្ពុជា (ព្រោះវាជាសាខារបស់ អង្គការទស្សឥតព្រំដែន អូស្ត្រាលី)។

4.2. គោលការណ៍គោលនយោបាយ

- ក្រុមការងារអង្គការទស្សនៈឥតព្រំដែនទាំងអស់មានកាតព្វកិច្ចរាយការណ៍អំពីទង្វើខុសឆ្គង ឬសង្ស័យថាប្រព្រឹត្តខុសដោយអនុលោមតាមគោលនយោបាយនេះ
- ក្រុមការងារអង្គការទស្សនៈឥតព្រំដែនទាំងអស់មានសិទ្ធិនិយាយដោយសេរី និងស្មោះត្រង់ ដើម្បីរាយការណ៍ពីទង្វើខុសឆ្គងនៅក្នុងបរិយាកាសសុវត្ថិភាពដោយមិនភ័យខ្លាចការសងសឹក ឬការផ្ចាញ់ផ្ចាល
- អង្គការទស្សនៈឥតព្រំដែន នឹងឆ្លើយតបទាន់ពេលវេលា ប្រកបដោយការគោរព និងសម្ងាត់ចំពោះការលាតត្រដាងទាំងអស់នៃអំពើខុសឆ្គង។
- អង្គការទស្សនៈឥតព្រំដែន នឹងដាក់ទោស ឬអនុវត្តទណ្ឌកម្មសមស្របផ្សេងទៀត ចំពោះអ្នកដែលបានប្រព្រឹត្តការក្លែងបន្លំ និងចូលរួមក្នុងការប្រព្រឹត្តអំពើពុករលួយ។

## 5. អនុវត្តន៍គោលនយោបាយ

5.1. រាយការណ៍ពីការព្រួយបារម្ភ

ការរាយការណ៍ពីកង្វល់ គួរតែត្រូវបានរាយការណ៍ដោយស្មោះត្រង់ទៅកាន់សមាជិក ក្រុមអ្នកដឹកនាំ អង្គការទស្សនៈឥតព្រំដែន នៅក្នុងប្រទេសដែលមានការព្រួយបារម្ភ ឬសមាជិកក្រុម

ប្រឹក្សាភិបាលណាមួយ។ ឧបសម្ព័ន្ធ ក នៃគោលការណ៍នេះមានព័ត៌មានលម្អិតពេញលេញអំពីអ្នកដែលត្រូវរាយការណ៍ទៅសម្រាប់ប្រទេសនីមួយៗ។

បុគ្គលរាយការណ៍មិនត្រូវទាក់ទងបុគ្គលដែលពាក់ព័ន្ធបទចោទប្រកាន់ដោយផ្ទាល់ទេ (ទោះក្នុងការបញ្ចប់រឿងដោយសម្ងាត់ ឬបែបណាក៏ដោយ) ឬព្យាយាមស៊ើបអង្កេតបញ្ហា នេះដោយផ្ទាល់ខ្លួនឡើយ។

## 5.2. ការស៊ើបអង្កេតលើករណីត្រូវបានរាយការណ៍

បុគ្គលមានសមត្ថកិច្ចចំពោះមុខព័ត៌មាន(បណ្តឹង)នឹងត្រូវ៖

- ធ្វើកំណត់ហេតុលម្អិតស្តីពីហេតុការណ៍ដែលត្រូវបានទម្លាយ
- សុំឱ្យអ្នកផ្តល់ព័ត៌មានផ្តល់សេចក្តីថ្លែងការណ៍ជាលាយលក្ខណ៍អក្សរដែល ពិពណ៌នាអំពីការចោទប្រកាន់ដោយសង្ខេប និងច្បាស់លាស់
- នៅពេលទទួលបានសេចក្តីថ្លែងការណ៍ជាលាយលក្ខណ៍អក្សរ បុគ្គលមានសមត្ថកិច្ចនោះនឹងបញ្ជូនព័ត៌មានទៅអ្នកដែលសមស្រប (សមាជិកនៃក្រុមអ្នកដឹកនាំ នាយកប្រតិបត្តិ ឬសមាជិកណាមួយនៃក្រុមប្រឹក្សាភិបាល ឬគណៈគ្រប់គ្រង) ហើយសរសេរទៅបុគ្គលិករាយការណ៍ក្នុងរយៈពេលប្រាំថ្ងៃធ្វើការយ៉ាងយូរអំឡុងការបញ្ជូនបណ្តឹង។ នៅក្នុងសំបុត្ររបស់ពួកគេ ពួកគេនឹងទទួលស្គាល់ការទទួលពាក្យបណ្តឹង ផ្តល់ព័ត៌មានអំពីអ្នកដែលវាត្រូវបានបញ្ជូនទៅ និងព័ត៌មានលម្អិតអំពីអ្នកដែល បុគ្គលិកគួរទាក់ទង ប្រសិនបើពួកគេមានសំណួរបន្ថែម។
- ក្នុងករណីដែលតម្រូវឱ្យមានសកម្មភាពបន្ថែមទៀត ការស៊ើបអង្កេតនឹងធ្វើឡើង ក្នុងទម្រង់នៃការស៊ើបអង្កេតផ្ទៃក្នុង។ អ្នកស៊ើបអង្កេតផ្ទៃក្នុងនឹងត្រូវជាសមាជិកនៃក្រុមអ្នកដឹកនាំ នាយកប្រតិបត្តិ ឬសមាជិកណាមួយនៃក្រុមប្រឹក្សាភិបាល ឬគណៈគ្រប់គ្រង (តាមការសមស្របតាមករណីនីមួយៗ)។

នៅពេលដែលការស៊ើបអង្កេតត្រូវបានបញ្ចប់ បុគ្គលរាយការណ៍នឹងត្រូវបានផ្តល់ការពន្យល់ភ្លាមៗ និងហ្មត់ចត់អំពីលទ្ធផលនៃការស៊ើបអង្កេត ហើយវិធានណាមួយដែល អង្គការទស្សនៈឥតព្រំដែន នឹងដាក់ចេញជាការឆ្លើយតបលទ្ធផលនៃការស៊ើបអង្កេតនោះ។

ចំពោះការចោទប្រកាន់ត្រូវបានចាត់ទុកថាមានលក្ខណៈធ្ងន់ធ្ងរ របាយការណ៍មួយនឹងត្រូវបានរៀបចំសម្រាប់ក្រុមប្រឹក្សាភិបាល។ ក្នុងករណីទាមទារការចូលរួមរបស់អជ្ញាធរខាងក្រៅ ដូចជា ប៉ូលីស ក្រុមACFID (នៅប្រទេសអូស្ត្រាលី) គណៈកម្មាធិការសប្បុរសធម៌ (ចក្រភពអង់គ្លេស) ឬ និយតករសប្បុរសធម៌ (អៀរឡង់)។

5.3. ការសម្ងាត់

ប្រសិនបើសកម្មភាពខុសឆ្គង ឬសកម្មភាពដែលសង្ស័យត្រូវបានរាយការណ៍នៅក្រោមគោលនយោបាយនេះ អង្គការទស្សនៈឥតព្រំដែន នឹងខិតខំការពារអត្តសញ្ញាណរបស់បុគ្គលរាយការណ៍។ ដើម្បីកុំឱ្យប៉ះពាល់ដល់ការស៊ើបអង្កេតលើទង្វើខុសឆ្គងនេះ បុគ្គលរាយការណ៍ក៏ត្រូវបានរំពឹងថានឹងរក្សាការពិតដែលពួកគេបានលើកឡើងពីការព្រួយបារម្ភ លក្ខណៈនៃការព្រួយបារម្ភ និងអត្តសញ្ញាណរបស់អ្នកពាក់ព័ន្ធជាសម្ងាត់។

ជាទូទៅ អង្គការទស្សនៈឥតព្រំដែន នឹងមិនបង្ហាញអត្តសញ្ញាណរបស់បុគ្គលរាយការណ៍ ឡើយ លុះត្រាតែ៖

- បុគ្គលរាយការណ៍យល់ព្រមចំពោះការលាតត្រដាង
- ការលាតត្រដាងត្រូវបានទាមទារ ឬអនុញ្ញាតដោយច្បាប់ និង/ឬ
- ការលាតត្រដាងគឺចាំបាច់ដើម្បីបន្តការស៊ើបអង្កេត និងការយល់ព្រមពីបុគ្គលរាយការណ៍។

ភាគច្រើន របាយការណ៍ដែលធ្វើឡើងក្រោមគោលនយោបាយនេះនឹងត្រូវបានចាត់ទុកជាសម្ងាត់។ ទោះយ៉ាងណាក៏ដោយនៅពេលដែលរបាយការណ៍ត្រូវបានស៊ើបអង្កេត វាអាចចាំបាច់ក្នុងការបង្ហាញការណ៍នេះទៅដល់មនុស្សផ្សេងទៀត ដូចជាបុគ្គលិកអង្គការទស្សនៈឥតព្រំដែន បុគ្គលខាងក្រៅដែលចូលរួមក្នុងដំណើរការស៊ើបអង្កេត និង ភ្នាក់ងារអនុវត្តច្បាប់ក្នុងកាលៈទេសៈចាំបាច់។ នៅចំណុចខ្លះ វាក៏អាចចាំបាច់ក្នុងការបង្ហាញការពិត និងខ្លឹមសារនៃរបាយការណ៍ទៅកាន់បុគ្គលដែលជាកម្មវត្ថុនៃរបាយការណ៍ផងដែរ។

អង្គការទស្សនៈឥតព្រំដែន នឹងចាត់វិធានការប្រុងប្រយ័ត្នសមហេតុផលដើម្បីរក្សាទុកកំណត់ត្រាណាមួយដែលទាក់ទងនឹងរបាយការណ៍នៃអំពើខុសឆ្គងដោយសុវត្ថិភាព និងអនុញ្ញាតឱ្យចូលប្រើបានសម្រាប់បុគ្គលិកដែលមានសិទ្ធិតែប៉ុណ្ណោះ។

ការលាតត្រដាងព័ត៌មានដោយគ្មានការអនុញ្ញាតទាក់ទងនឹងរបាយការណ៍, អត្តសញ្ញាណរបស់បុគ្គលរាយការណ៍ ឬព័ត៌មានដែលបញ្ជាក់ពីអត្តសញ្ញាណរបស់បុគ្គលរាយការណ៍ នឹងត្រូវបានចាត់ទុកជាកំហុសធ្ងន់ធ្ងរ ហើយអាចបណ្តាលឱ្យមានការវិន័យ ដែលអាចឈានដល់ការបណ្តេញចេញផងដែរ។

5.4. ការការពារបុគ្គលរាយការណ៍

គ្មានបុគ្គលណាដែលលើកឡើងពីការព្រួយបារម្ភដោយស្មោះត្រង់ក្រោមគោលនយោបាយនេះ នឹងត្រូវបានបណ្តេញចេញ ឬទទួលរងនូវការខូចខាតណាមួយជាលទ្ធផល នៃសកម្មភាពនេះទេ បើទោះបីជាការព្រួយបារម្ភនេះប្រែជាគ្មានមូលដ្ឋានក៏ដោយ។ ការខូចខាតដែលលើកឡើងខាងដើមរួមមាន (ប៉ុន្តែមិនកំណត់ចំពោះ) បទវិធានវិន័យដែលមិនយុត្តិធម៌ និងការធ្វើឱ្យបុគ្គលរាយការណ៍ត្រូវរងគ្រោះក្នុងទម្រង់ណាមួយខាងក្រោម៖

- ការបណ្តេញចេញ
- ការទម្លាក់តំណែង
- ទម្រង់នៃការបៀតបៀនណាមួយ
- ការរើសអើង
- ភាពលំអៀងបច្ចុប្បន្ន ឬអនាគត
- ការគំរាមកំហែងនៃទម្រង់ណាមួយខាងលើ

រាល់សកម្មភាពសងសឹកបែបនេះ នឹងត្រូវចាត់ទុកជាទង្វើខុសឆ្គងធ្ងន់ធ្ងរ ហើយនឹងបណ្តាលឱ្យមានវិធានការវិន័យ ដែលអាចរាប់បញ្ចូលទាំងការបណ្តេញចេញ។ ប្រសិនបើបុគ្គលរាយការណ៍ជឿថាសកម្មភាពសងសឹកបានកើតឡើង ឬត្រូវបានគំរាមកំហែង បុគ្គលរាយការណ៍មានសិទ្ធិក្នុងការដាក់ស្នើទៅក្រុមប្រឹក្សាភិបាលអូស្ត្រាលីបាន។ ក្រុមប្រឹក្សាភិបាលអូស្ត្រាលី គឺមានភាពឯករាជ្យ ហើយនឹងធ្វើការសម្រេចចិត្តលើបញ្ហានេះ។

5.5. បុគ្គលរាយការណ៍ជាប់ពាក់ព័ន្ធនឹងទង្វើខុសច្បាប់

ទោះបីជាបុគ្គលរាយការណ៍អាចជាប់ពាក់ព័ន្ធក្នុងទង្វើខុសច្បាប់ក៏ដោយ ពួកគេនឹងមិនត្រូវបានកំណត់ជាមុខសញ្ញាសម្រាប់សកម្មភាពសងសឹកជាក់ស្តែង ឬគំរាមកំហែង ឬធ្វើឱ្យរងគ្រោះក្នុងការសងសឹកចំពោះការរាយការណ៍ក្រោមគោលនយោបាយនេះទេ។

យ៉ាងណាក៏ដោយ ការរាយការណ៍នឹងមិនអាចជារនាំងការពារបុគ្គលរាយការណ៍ ពីផលវិបាកដែលកើតចេញពីការចូលរួមរបស់បុគ្គលនោះនៅក្នុងទង្វើខុសនោះទេ។ក្នុងកាលៈទេសៈខ្លះ ការសារភាពកំហុសអាចជាកត្តាកាត់បន្ថយនៅពេលពិចារណាលើវិន័យ ឬសកម្មភាពផ្សេងទៀត។

### 5.6. ការផ្ដល់ពត៌មានមិនពិត

អង្គការទស្សនៈឥតព្រំដែន នឹងចាត់ចែងរាល់ការលាតត្រដាងនៃអំពើខុសឆ្គងយ៉ាងហ្មត់ចត់ នឹងការពារបុគ្គលដែលលើកឡើងការព្រួយបារម្ភដោយចេតនាល្អ។ ទោះបីជាយ៉ាងណាក៏ដោយ ខណៈពេលដែលការការពារត្រូវបានផ្តល់ជូនអ្នករាយការណ៍នៅក្រោមគោលនយោបាយនេះ ការរាយការណ៍មិនពិតដោយចេតនា នឹងមិនត្រូវបានអត់ឱនឱ្យទេ ហើយនរណាម្នាក់ដែលបានរកឃើញថាមានការទាមទារ ឬរាយការណ៍មិនពិតដោយចេតនា នឹងត្រូវទទួលរងនូវវិធានការវិន័យ រួមទាំងការបណ្តេញចេញផងដែរ។

### 5.7. ការប្រាស្រ័យទាក់ទងជាមួយបុគ្គលរាយការណ៍

បុគ្គលរាយការណ៍ នឹងត្រូវបានជូនដំណឹងអំពីវឌ្ឍនភាពនៃការស៊ើបអង្កេត។ បុគ្គលរាយការណ៍នឹងត្រូវបានជូនដំណឹងអំពីលទ្ធផលនៃការស៊ើបអង្កេត តែអាស្រ័យលើការពិចារណាអំពីភាពឯកជនរបស់អ្នកដែលរងនូវការចោទប្រកាន់ត្រូវបានធ្វើឡើង។

### 5.8. ការគ្រប់គ្រងបុគ្គលដែលរងនូវការចោទប្រកាន់

ជាទូទៅ បុគ្គលដែលជាកម្មវត្ថុនៃការចោទប្រកាន់ណាមួយដែលត្រូវបានស៊ើបអង្កេត នឹងត្រូវៈ

- ត្រូវបានជូនដំណឹងអំពីខ្លឹមសារនៃការចោទប្រកាន់
- ត្រូវបានផ្តល់ឱកាសដើម្បីឆ្លើយតបការចោទប្រកាន់ មុនពេលការស៊ើបអង្កេត ណាមួយត្រូវបានបញ្ចប់
- ត្រូវបានគេជូនដំណឹងអំពីខ្លឹមសារនៃមតិយោបល់អវិជ្ជមានដែលអាចត្រូវបានរួម បញ្ចូលនៅក្នុងរបាយការណ៍ណាមួយដែលកើតឡើងពីការស៊ើបអង្កេត មុនពេលវាត្រូវបានបញ្ចប់
- មានសិទ្ធិការពារខ្លួនដោយយុត្តិធម៌ទល់របាយការណ៍ណាមួយ

អង្គការ ទស្សនៈឥតព្រំដែន ទទួលស្គាល់ថាបុគ្គលដែលត្រូវបានចោទប្រកាន់ ត្រូវទទួលបានការគាំទ្រផងដែរ កំឡុងដំណើរការស៊ើបអង្កេតកំហុស។ អង្គការ ទស្សនៈឥតព្រំដែន នឹងអនុវត្តគ្រប់ជំហានសមហេតុសមផលដើម្បីធានាថាបុគ្គលត្រូវបានចោទប្រកាន់ ត្រូវបានប្រព្រឹត្តដោយយុត្តិធម៌ ជាពិសេសក្នុងដំណើរការស្ដាប់ស្ទង់និងស៊ើបអង្កេត។ ការគាំទ្រផ្ដល់ដោយ អង្គការ ទស្សនៈឥតព្រំដែន អាចមានដូចជាការបញ្ជូនឱ្យទទួលបានការប្រឹក្សាយោបល់។

## 6. គោលនយោបាយពាក់ព័ន្ធ

- គោលនយោបាយកំហុសឆ្គងផ្នែកហិរញ្ញវត្ថុ
- គោលនយោបាយការគ្រប់គ្រងបណ្ដឹង និងមតិកែលម្អ
- គោលនយោបាយកិច្ចការពារសុវត្ថិភាព

## 7. ការគ្រប់គ្រងគោលនយោបាយ

គោលនយោបាយនេះត្រូវបានអនុម័តដោយក្រុមប្រឹក្សាភិបាលអូស្ត្រាលី និងគណៈកម្មាធិការ នៃអង្គភាពផ្សេងទៀតរបស់ អង្គការទស្សនៈឥតព្រំដែន ដូចដែលបានកត់សម្គាល់ខាងក្រោម។

វិសោធនកម្ម និង ឬការអភិវឌ្ឍន៍នឹងត្រូវបានណែនាំដល់ក្រុមប្រឹក្សាភិបាលពីមួយពេលទៅមួយពេល តាមការយល់ឃើញថាសមស្របដោយអ្នកគ្រប់គ្រងជាន់ខ្ពស់។ ការត្រួតពិនិត្យជាផ្លូវការ នឹងប្រព្រឹត្តទៅមុនពេលផុតកំណត់រយៈពេលបីឆ្នាំគិតចាប់ពីថ្ងៃខួបនៃការអនុម័តដោយ ក្រុមប្រឹក្សាភិបាល។ អនុសាសន៍សម្រាប់ការផ្លាស់ប្ដូរតិចតួចអាចត្រូវបានអនុម័តដោយនាយក ប្រតិបត្តិមុនពេលផុតកំណត់រយៈពេល 3 ឆ្នាំ ហើយអនុសាសន៍សម្រាប់ការផ្លាស់ប្ដូរផ្ទៃក្នុង ឬគោលនយោបាយក្នុងការអនុវត្តអាចត្រូវបានអនុម័តដោយអនុគណៈកម្មាធិការដែលពាក់ព័ន្ធ។

| Doc ref | Doc type | Approved by Australian Board Date | Minute ref. | Approved by UK Trustees Date | Minute ref | Approved by Irish Board Date | Minute ref |
|---|---|---|---|---|---|---|---|
| WP/06/2020/1.0 | Policy Review | Board June 29 2020 | Agenda item 8 | July 21 2020 | Agenda item 5 | | |
| WP/06/2020/1.1 | Policy Amendment | CEO Note 11 Nov 2020 | | CEO Note 11 Nov 2020 | | | |

## ឧបសម្ព័ន្ធ ក - នីតិវិធីរាយការណ៍

**នៅកម្ពុជា៖**

ការរាយការណ៍ក្តីព្រួយបារម្ភ គួរតែត្រូវបានរាយការណ៍ទៅ Derek Culligan អ្នកគ្រប់គ្រងទូទៅផ្នែក ធនធានមនុស្ស និងហិរញ្ញវត្ថុ៖

derek.culligan@seebeyondborders.org +855 (0)63 5070 888

ប្រសិនបើបុគ្គលរាយការណ៍មិនសប្បាយចិត្តក្នុងការរាយការណ៍ទៅមនុស្សខាងលើ ពួកគេគួរតែទាក់ទងសមាជិកណាម្នាក់ទៀតនៃក្រុមអ្នកដឹកនាំនៅកម្ពុជា។

**នៅអូស្ត្រាលី៖**

ការរាយការណ៍ក្តីព្រួយបារម្ភ គួរតែត្រូវបានរាយការណ៍ទៅ Sally Miles, ជានាយិកាប្រតិបត្តិ តាមសារអេឡិចត្រូនិច sally.miles@seebeyondborders.org Tel: +61 (0)2 9960 7077 ប្រសិនបើអ្នករាយការណ៍មិនសប្បាយចិត្តក្នុងការរាយការណ៍ទៅមនុស្សខាងលើ ពួកគេគួរតែទាក់ទងសមាជិកណាម្នាក់ទៀតនៃក្រុមប្រឹក្សាភិបាលអូស្ត្រាលី ។

**នៅក្នុងចក្រភពអង់គ្លេស៖**

ការរាយការណ៍ក្តីព្រួយបារម្ភ គួរតែត្រូវបានរាយការណ៍ទៅ Caroline Abel ហិរញ្ញិកនៃក្រុមប្រឹក្សាភិបាល caroline@abelbase.com +44 (0)7910 145210

ប្រសិនបើអ្នករាយការណ៍មិនសប្បាយចិត្តក្នុងការរាយការណ៍ទៅមនុស្សខាងលើ ពួកគេគួរតែទាក់ទងសមាជិកណាម្នាក់ទៀតនៃក្រុមប្រឹក្សាភិបាលដែលមានក្នុងតំណរភ្ជាប់នេះ https://www.seebeyondborders.org/structure-and-governance/

**នៅប្រទេសអៀរឡង់៖**

ការរាយការណ៍ក្តីព្រួយបារម្ភ គួរតែត្រូវបានរាយការណ៍ទៅលោកស្រី Maeve Corish ប្រធានក្រុមប្រឹក្សាភិបាល maeve.corish@seebeyondborders.org, +353 (0)86 375 6554

ប្រសិនបើអ្នករាយការណ៍មិនសប្បាយចិត្តក្នុងការរាយការណ៍ទៅមនុស្សខាងលើ ពួកគេគួរតែទាក់ទងសមាជិកណាម្នាក់ទៀតនៃក្រុមប្រឹក្សាភិបាលដែលមានក្នុងតំណរភ្ជាប់នេះ https://www.seebeyondborders.org/structure-and-governance/